ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១៥ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រឹត្យ

២៧-៤-១៩៩៥ - ព្រះរាជក្រឹត្យលេខ នស/រកត ០៤៩៥/៤២ .... ៦១៨

២៧-៤-១៩៩៥ - ព្រះរាជក្រឹត្យលេខ នស/រកត ០៤៩៥/៤៣ .... ៦១៩

២៧-៤-១៩៩៥ - ព្រះរាជក្រឹត្យលេខ នស/រកត ០៤៩៥/៤៤ .... ៦២០

II- ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

២៦-៤-១៩៩៥ - អនុក្រឹត្យលេខ ៤៨ អនក្រ ស្ដីពីការប្រគល់សិទ្ធិចុះហត្ថលេខាលើ
អត្តសញ្ញាណ ប័ណ្ណ នាយទាហាន នាយទាហានរង និង ពលទាហាន
ទូទាំងកងយោធពលខេមរភូមិន្ទ........................ ៦២០

២៧-៤-១៩៩៥ - អនុក្រឹត្យលេខ ៤៩ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦២២

២៧-៤-១៩៩៥ - អនុក្រឹត្យលេខ ៥០ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦២៣

២. សេចក្ដីសំរេច

២៦-៤-១៩៩៥ - សេចក្ដីសំរេចលេខ ៣៨ សសរ ស្ដីពីការបង្កើតគណៈកម្មការចំរុះសំរាប់
សហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋបារាំង ៦២៤

៣. សេចក្ដីប្រកាស

២៨-៤-១៩៩៥ - សេចក្ដីប្រកាសលេខ ០៣ ប្រ.ក ស្ដីពីនយោបាយព្រៃឈើ ៦២៦

III- ការងារបណ្តាក្រសួង

១. ធីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

២៧-៤-១៩៩៩ - ប្រកាសលេខ ៥៩ រប.៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាវិន័យប្រចាំក្រសួងយុត្តិធម៌ ៦២៨

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៦-៤-១៩៩៩ - ប្រកាសលេខ ៣១០ ឧក.ប្រក អនុញ្ញាតអោយលោក គាត ចំរើន ជនជាតិខ្មែរ បើកដំណើរការឡជះនតឥដ្ឋស៊ីម៉ង់ត៍គ្រប់ប្រភេទ ៦២៩

៣. ធីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

២៨-៤-១៩៩៩ - ប្រកាសលេខ ០៩២/៩៩ ពម.ប្រក ស្តីពីការអនុញ្ញាតអោយបោះពុម្ពផ្សាយសារពត៌មានឈ្មោះ " សង្គ្រោះខ្មែរ " ៦៣១

៤. ធីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

២៤-៤-១៩៩៩ - ប្រកាសលេខ ៩១ ប្រក.វវស.ប ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ មន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៦៣២

២៧-៤-១៩៩៥ - ប្រកាសលេខ ៥៨ ប្រក.វវស.ឬ ស្តីពីការលុបឈ្មោះមន្ត្រីរាជការមន្ទីរវប្បធម៌
និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៦៣៣

៦. ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

២៥-៤-១៩៩៥ - ប្រកាសលេខ ៨១/៩៥ កធស/ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ៦៣៤

២៥-៤-១៩៩៥ - ប្រកាសលេខ ៨២ កធស.ប្រក ស្តីពីការបញ្ចូលមន្ត្រីរាជការ អោយបំរើ
ការងារក្នុងមន្ទីរធម្មការ និង សាសនា ខេត្តកំពង់ឆ្នាំង.............................. ៦៣៥

៥. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

២៨-៤-១៩៩៥ - សេចក្តីសំរេចលេខ ២៤៧ មស.ក្រខ ស្តីពីការកែតំរូវសេចក្តីសំរេច
លេខ ១៧៥ សសរ មស.ក្រខ ចុះថ្ងៃទី ២៣/៣/១៩៩៥ .... ៦៣៦

I- ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៤២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ចរិន្ទ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨

ព្រះរាជក្រឹត្យ... ព្រះរាជ...

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយទោសរយៈពេល ០៩ ខែ អោយទណ្ឌិតចំនួន ០២ នាក់ ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ដូចបានរាយនាមខាងក្រោមនេះ :

១_ទណ្ឌិតឈ្មោះ **នាង ចន្ថា** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ១៩៩១ របស់តុលាការយោធា ។

២_ទណ្ឌិតឈ្មោះ **ហ៊ុំ ណារិត** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៩ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៩២ របស់តុលាការយោធា ។

មាត្រា ២ : ត្រូវបន្ថយទោសរយៈពេល ០៦ ខែអោយទណ្ឌិតចំនួន ០១ នាក់ដែលបានកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោស ដូចបានរាយនាមខាងក្រោមនេះ :

១_ទណ្ឌិតឈ្មោះ **ចុន សុខន** ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩២ របស់តុលាការយោធា ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃ ឡាយព្រះហស្ថលេខានេះតទៅ ។

មាត្រា ៤ ៖ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេច ជាស្ថាពរ ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៥/៤៣

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ៖ តែងតាំងឯកឧត្តម **ម៉ែ សំអឿន** ជាទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ទទួលបន្ទុកកិច្ចការកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ ៖ នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជ ក្រឹត្យនេះ ។

មាត្រា ៣ ៖ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៥/៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិក មហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ : ត្រូវលើកលែងទោសអោយទណ្ឌិតឈ្មោះ **ខែម ឡាក់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំតាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ១.៨.៨៦ របស់តុលាការខេត្ត សៀមរាប-ឧត្តរមានជ័យ ។

មាត្រា ២ : ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

មាត្រា ៣ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II- ទីស្តីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៨ អនក្រ
ស្តីពីការប្រគល់សិទ្ធិ ចុះហត្ថលេខា លើ

អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង និង ពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការ នៃកងទ័ពជាតិកម្ពុជា

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់សិទ្ធិ ជូនរដ្ឋមន្ត្រីក្រសួងការពារជាតិ ចុះហត្ថលេខាលើ អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង ពលទាហាន ក្នុងកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចប្រគល់សិទ្ធិជូនអាជ្ញាធរយោធាមាន សមត្ថកិច្ចនៃកងយោធពលខេមរភូមិន្ទ ចុះហត្ថលេខាលើអត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង ពលទាហាន ។

មាត្រា ៣ : រាល់បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ ត្រូវទទួលបន្ទុកអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៩ អនក្រ.កត
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនសប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិកដូចមានរាយនាមខាងក្រោម ÷

១-លោក **បាន ឌឿន** និងអ្នកស្រី **អ៊ុច រ៉ត** ដែលមានចិត្តសប្បុរសបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមកសាងសាលាធម្មសភា និងសាលារៀននៅស្រុកឯកភ្នំ ខេត្តបាត់ដំបង អស់ទឹកប្រាក់សរុប ៨៥.៦០០ $ ដុល្លារអាមេរិក ។

២-លោក **សាំង សារិន** និងអ្នកស្រី **ឆាយ ឈូ** ដែលមានចិត្តសប្បុរសបរិច្ចាគថវិកាផ្ទាល់ខ្លួនចូលរួមកសាងសាលារៀននៅស្រុកឯកភ្នំ ខេត្តបាត់ដំបង អស់ទឹកប្រាក់ សរុប ១០.៥០០ $ ដុល្លារអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៥០ អនក្រ.គត
ស្ដីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាលស្ដីពីការបង្កើត និងប្រើប្រាស់មេដាយស្ថាបនាជាតិ និងប័ណ្ណស្ថាបនាជាតិ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ២ ជូនចំពោះលោក **ហាន់ ចេនកុខ** ក្រុមហ៊ុន SL INTERNATIONAL LTD ដែលបានបរិច្ចាគប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិកសំរាប់ឧបត្ថម្ភដល់ប្រជារាស្ត្រក្រីក្រ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ : ៣៨ សសរ
ស្តីពីការបង្កើតគណៈកម្មការចំរុះសំរាប់សហប្រតិបត្តិការ
រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋបារាំង

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការចំរុះសំរាប់សហប្រតិបត្តិការ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋបារាំងដែលមានសមាសភាពដូចខាងក្រោម :

១_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	ជាប្រធាន
២_តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក

៣_តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

៤_តំណាងក្រសួងផែនការ ជាសមាជិក

៥_តំណាងក្រសួងអប់រំយុវជន និង កីឡា ជាសមាជិក

៦_តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាសមាជិក

៧_តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៨_តំណាងក្រសួងការពារជាតិ ជាសមាជិក

៩_តំណាងក្រសួងសុខាភិបាល ជាសមាជិក

១០_តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

១១_តំណាងក្រសួងយុត្តិធម៌ ជាសមាជិក

១២_តំណាងក្រសួងពត៌មាន ជាសមាជិក

១៣_តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាសមាជិក

១៤_តំណាងក្រសួងពាណិជ្ជកម្ម ជាសមាជិក

១៥_តំណាងក្រសួងទេសចរណ៍ ជាសមាជិក

១៦_តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

១៧_តំណាងរាជធានីភ្នំពេញ ជាសមាជិក

១៨_តំណាងអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ជាសមាជិក

១៩_មន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាលេខាធិការ

ប្រការ ២ ៖ គណៈកម្មការចំរុះនេះមានភារកិច្ច ៖

_កំណត់ឡើងនូវគោលដៅជាយុទ្ធសាស្ត្រក្នុងការទំនាក់ទំនងនយោបាយសេដ្ឋកិច្ចកម្ពុជា_បារាំង

_កំណត់ឡើងនូវគោលនយោបាយសំរាប់ពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ

_កសាងផែនការសហប្រតិបត្តិការសេដ្ឋកិច្ច និង គំរោងការណ៍ជាអាទិភាពតាមផ្នែក ។

_កសាងកម្មវិធីធ្វើការ របស់គណៈកម្មការចំរុះ

_រៀបចំខ្លឹមសារចរចា, ឯកសារ , លិខិតដែលទាក់ទងដល់ការព្រមព្រៀងសំរាប់ការ ចុះហត្ថលេខាទ្វេភាគី ។

-ត្រួតពិនិត្យតាមដាន ជំរុញការអនុវត្តន៍ផែនការ និង គំរោងការណ៍នីមួយៗ និងដាក់វិធានការសំដៅធ្វើអោយសំរេចស្របតាមកិច្ចសន្យា និងកាលបរិច្ឆេទកំណត់ ។

-ប្រមូលព័ត៌មាន ផ្លាស់ប្តូរព័ត៌មាន ធ្វើរបាយការណ៍ ។

ប្រការ ៣ : សមាជិកទាំងអស់នៃគណៈកម្មការនេះ ត្រូវចូលរួមធ្វើការងារ និង ប្រជុំតាមសេចក្តីអញ្ជើញ របស់ប្រធាន ។

ប្រការ ៤ : [illegible] មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាផ្លូវការ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុងភ្នំពេញ ប្រធានអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់តាំងពី ថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

***

៣- សេចក្តីប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីប្រកាសលេខ : ០៣ ប្រក
របស់រាជរដ្ឋាភិបាលកម្ពុជា
ស្តីពីនយោបាយព្រៃឈើ

ដោយយល់ឃើញថា ព្រៃឈើមានសារៈសំខាន់បំផុត សំរាប់ប្រទេសជាតិ និង ប្រជាជនកម្ពុជាទាំងមូលរាជរដ្ឋាភិបាលកម្ពុជា បានសំរេចដាក់ចេញនូវគោលនយោបាយ យ៉ាងច្បាស់លាស់មួយដើម្បីការពារព្រៃឈើដែលជាសម្បត្តិដ៏មានតំលៃរបស់ជាតិខ្មែរ ។

គោលនយោបាយនេះបានកំណត់នូវវិធានការមួយចំនួនដូចខាងក្រោមនេះ :

១_បញ្ឈប់ការដេញថ្លៃព្រៃគុប ,ការនាំចេញឈើមូល_ឈើអារ ចាប់ពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៥ នេះតទៅ ។ ចំពោះឈើដែលកាប់ហើយ នៅសេសសល់ត្រូវទុកសំរាប់ការប្រើប្រាស់ក្នុងស្រុក ។

២_ដើម្បីធានាអោយការគ្រប់គ្រងបានល្អ និង ការធ្វើអាជីវកម្មព្រៃឈើ មានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់រាជរដ្ឋាភិបាលកម្ពុជាអនុគ្រោះ អោយមានព្រៃសម្បទានសំរាប់ការវិនិយោគសំខាន់ៗ ។

ការកំណត់ព្រៃសម្បទាន ត្រូវគោរពយ៉ាងតឹងរ៉ឹងស្របតាមនយោបាយការពារបរិដ្ឋាន និងច្បាប់ការពារព្រៃឈើអន្តរជាតិ (ITTO) :

-ត្រូវបង្ហាញជាចាំបាច់នូវផែនការមេ សំរាប់ការរៀបចំ និងការដាំដើមឈើឡើងវិញ របស់ព្រៃសម្បទាន ។

-គោរពដាច់ខាតនូវបណ្តាឧទ្យានជាតិ ដែលបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

-បណ្តាព្រៃសម្បទាន ដែលបានអនុញ្ញាតរួចហើយ ត្រូវបង្ហាញលក្ខខ័ណ្ឌ អាជីវកម្មស្របតាមបទបញ្ញត្តិខាងលើនេះ ។

-ពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីសំរបសំរួលការត្រួតពិនិត្យការនាំឈើចេញ និងការការពារធនធានធម្មជាតិ និង បរិដ្ឋាន ។

-ពង្រីកមនសិការ អំពីការការពារបេតិកភ័ណ្ឌជាតិ ដើម្បីអោយពលរដ្ឋម្នាក់ៗរួម ចំណែកសង្គ្រោះដោយការដាំដើមឈើឡើងវិញ ដោយមានការចាប់អារម្មណ៍ និង អប់រំសាធារណៈ ។

-ធ្វើអោយមានដំណើរការឡើងវិញ នូវការស្រាវជ្រាវ អនុវត្តព្រៃឈើ ដោយធ្វើអោយមាននិតិសម្បទាឡើងវិញនូវយន្តការពិសោធន៍ផ្សេងៗ ។

-ការរៀបចំព្រៃឈើ ដោយប្រមូលការប្រឹងប្រែង ផ្តោតលើភូមិភាគសំខាន់ៗ៣ដូចតទៅ :

ក-ព្រៃឈើនៃភូមិភាគភ្នំក្រវាញ ភូមិភាគឆ្នេរសមុទ្រ ពោធិសាត់ និង បាត់ដំបង ។

ខ-ព្រៃឈើខេត្ត កំពង់ធំ និង មេគង្គត្រើយស្តាំ ។

គ-ព្រៃឈើខេត្ត ស្ទឹងត្រែង និង មេគង្គត្រើយឆ្វេង ។

-រាជរដ្ឋាភិបាលនិងពិនិត្យដោយហ្មត់ចត់បំផុត ចំពោះគំរោងអំពីព្រៃសម្បទានទាំងឡាយ ស្របតាមគោលការណ៍ និងវិធានការសំខាន់ៗដូចពោលខាងលើ ។

រាជរដ្ឋាភិបាលសង្ឃឹមជឿជាក់ថា នយោបាយព្រៃឈើនេះពិតជានឹងបានរួមចំណែកកាន់តែខ្លាំងក្លាថែមទៀត ដល់ការការពារធនធានធម្មជាតិ និង បរិដ្ឋាន ហើយក៏ជាការឆ្លុះបញ្ចាំងអោយឃើញនូវឆន្ទៈ ដ៏មោះមុតរបស់រាជរដ្ឋាភិបាល កន្លងមកក៏ដូចជាតទៅអនាគតដែរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

III- ការងារបណ្តាក្រសួង

១- ធរស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៥៩ រប.៩៥

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញសេចក្តីសំរេចលេខ ១២៨ ក.ប.៨០ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៨០ ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានឃើញច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជាដែលបានប្រកាសអោយប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣

សំរេច

មាត្រា ១ : បង្កើតក្រុមប្រឹក្សាវិន័យប្រចាំក្រសួងយុត្តិធម៌ ដើម្បីទទួលពិនិត្យ ស្រាវជ្រាវ ដោះស្រាយរាល់ពាក្យបណ្តឹង ហើយនឹងដាក់វិន័យចំពោះក្រឡាបញ្ជី នៅតាមសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ និងនៅក្រសួងយុត្តិធម៌ដែលបានប្រព្រឹត្តល្មើស ច្បាប់ក្នុងការងាររបស់ខ្លួន ។

មាត្រា ២ : ក្រុមប្រឹក្សាវិន័យមានសមាសភាពដូចខាងក្រោម ÷

១-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ តំណាង	ជាប្រធាន
២-ប្រធាននាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល	ជាអនុប្រធាន
៣-តំណាងអង្គភាពសាមី	ជាសមាជិក
៤-ក្រឡាបញ្ជី ១ នាក់ ក្នុងជំនាន់ជាមួយ	ជាសមាជិក
៥-ប្រធានការិយាល័យបុគ្គលិក ឬ តំណាង	លេខាធិការ

មាត្រា ៣ : អង្គភាពនានាក្រោមឱវាទក្រសួងយុត្តិធម៌ និង សាលាជំរះក្តីគ្រប់ជាន់ថ្នាក់ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ជែម ស្ងួន

* * *

២. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៣១០ ឧក.ប្រក

រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់សម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម

-បានឃើញពាក្យស្នើសុំ បើកដំណើរការឡផលិតឥដ្ឋ ស៊ីម៉ងត៍គ្រប់ប្រភេទរបស់លោក តាត ចំរើន ចុះថ្ងៃទី ១៨-៣-៩៥

-បានឃើញការយល់ព្រមរបស់ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ លេខ ១៧៥ ប.ជ ចុះថ្ងៃទី ០៣-៤-៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយ ឡផលិតឥដ្ឋ ស៊ីម៉ងត៍គ្រប់ប្រភេទ ដែលមានលោក តាត ចំរើន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២០៩៥១ ភ.រ ចុះថ្ងៃទី ២៣-៣-៩១ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៣១ ផ្លូវលេខ ៦៣ សង្កាត់ បឹងកេងកងទី១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្ម នៅក្នុងទីតាំង ភូមិអូរអណ្តូង សង្កាត់ ព្រែកប្រា ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក តាត ចំរើន ត្រូវចាប់ផ្តើមរៀបចំឡផលិតឥដ្ឋស៊ីម៉ងត៍គ្រប់ប្រភេទ របស់ខ្លួនអោយស្រេចជាស្ថាពរ ក្នុងរយៈពេលប្រាំមួយខែ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើប្រកាសនេះ ។ ហួសពេលកំណត់ប្រកាសនេះត្រូវចាត់ទុក ជាមោឃៈ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃរយៈពេល បីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៩២/៩៥ ពម.ប្រក

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារព័ត៌មាន ត្រូវបានរដ្ឋសភានៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ និតិកាលទី ១ ។
- បានឃើញលិខិតរបស់លោក ខេក សន ស្នើសុំអនុញ្ញាតបោះពុម្ពផ្សាយសារព័ត៌មាន "សង្គ្រោះខ្មែរ" ចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយដំណើរការបោះពុម្ពផ្សាយសារព័ត៌មានឈ្មោះ " សង្គ្រោះខ្មែរ " ដោយមានលោក **ខេក សន** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទនិងសកម្មភាពផ្សព្វផ្សាយត្រូវស្របតាមទំនៀមទំលាប់ប្រពៃណីល្អ និងច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពតាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និងឈរលើស្មារតីទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈ របស់ខ្លួននិងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់មកតំកល់ទុកជាឯកសារនៅក្រសួងព័ត៌មាន ។

ប្រការ ៤ : លោកចាងហ្វាងការផ្សាយសារព័ត៌មាន " សង្គ្រោះខ្មែរ " និងនាយកដ្ឋានមណ្ឌលព័ត៌មាន នៃក្រសួងព័ត៌មានត្រូវអនុវត្តនូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខានិងត្រា
ខៀវ កាញារីទ្ធ

* * *

៤.ធីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៩៦ ប្រក.វចស.ប
ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ
មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញ

រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំផ្ទេររបស់លោក ព្រហ្ម គន្ធ ប្រធានការិយាល័យនៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញអោយទៅបំរើការងារនៅមន្ទីរគ្រប់គ្រងបរិដ្ឋានរាជធានីភ្នំពេញ នៃក្រសួងគ្រប់គ្រងបរិដ្ឋាន របស់ប្រតិភូរាជ រដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

សំរេច

មាត្រា ១ : លោក **ព្រហ្ម គន្ធ** ប្រធានការិយាល័យ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ ត្រូវបានអនុញ្ញាតអោយផ្លាស់ទៅបំរើការងារនៅមន្ទីរគ្រប់គ្រងបរិដ្ឋានរាជធានីភ្នំពេញក្រោមឱវាទក្រសួងគ្រប់គ្រងបរិដ្ឋាន។

មាត្រា ២ : មន្ទីរវប្បធម៌ និង វិចិត្រសិល្បរាជធានីភ្នំពេញ ត្រូវផ្ទេរប្រាក់បៀវត្ស និងរបបឧបត្ថម្ភផ្សេងៗ របស់សាម៉ីខ្លួន និង ក្របខ័ណ្ឌមួយកន្លែងជូនមន្ទីរគ្រប់គ្រងបរិដ្ឋានរាជធានីភ្នំពេញ ។

មាត្រា ៣ : នាយកដ្ឋានបុគ្គលិកនិងកិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញនិងសាម៉ីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ស៊ីសុវត្ថិ ស៊ីរីវុធ ប៉ាណារ៉ា

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៩៨ ប្រក.វបស.បុ
ស្តីពីការលុបឈ្មោះមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈរាជធានីភ្នំពេញ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើសុំលុបឈ្មោះលេខ ៨៨ បជ. ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥របស់មន្ទីរវប្បធម៌ និងវិចិត្រ សិល្បៈ រាជធានីភ្នំពេញ ។

សំរេច

មាត្រា ១ : លោក **អ៊ុំ ស៊ីវណ្ណា** បុគ្គលិកការិយាល័យវប្បធម៌ និងវិចិត្រសិល្បៈខ័ណ្ឌមករា នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញពីបញ្ជីក្រប ខ័ណ្ឌមន្ត្រីរាជការ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៥ ដោយសុំលាឈប់ពីការងារ និង បានទទួលប្រាក់របបឧបត្ថម្ភគោលនយោបាយតាមការកំណត់ ។

មាត្រា ២ : នាយកដ្ឋានបុគ្គលិកនិងកិច្ចការសង្គម នាយកដ្ឋានផែនការគណនេយ្យ និង ហិរញ្ញវត្ថុ មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ រាជធានីភ្នំពេញ និង សាមីខ្លួនទទួលការកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

នុក ណារ៉ាង

* * *

៥. ទីស្តីការក្រសួងធម្មការ និង សាសនា

ប្រកាស

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៨១/៩៥ កធស.ប្រក

ស្តីអំពីការលុបឈ្មោះមន្ត្រីរាជការ

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៨២ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៨២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញលិខិតលេខ ១០ មធ-កច ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់មន្ទីរធម្មការ និង សាសនា ខេត្តកំពង់ចាម ។

សំរេច

ប្រការ ១ : លុបឈ្មោះលោក **ជុំ ជិន** បុគ្គលិកការិយាល័យធម្មការនិងសាសនា ស្រុកពញាក្រែក ចេញពីក្របខ័ណ្ឌរដ្ឋ ។

ប្រការ ២ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់លោក **ជុំ ខិន** ចាប់ផ្តាច់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៥ តទៅ ។

ប្រការ ៣ : មន្ទីរធម្មការនិងសាសនាខេត្ត មន្ទីរហិរញ្ញវត្ថុខេត្ត មន្ទីរផែនការខេត្តកំពង់ចាមត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

ប្រការ ៤ : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការនិងសាសនា

ហត្ថលេខានិងត្រា

ហៀង ចណ្ណារិទ្ធ

***

រាជធានីភ្នំពេញ ,ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ : ៨២/៩៥ ប្រក

ស្តីពីការបញ្ចូលមន្ត្រីរាជការអោយបំរើការងារ

ក្នុងមន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី ០១-១១-១៩៩៣

-បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

-បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ មិថុនា ១៩៩២ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។

-បានឃើញពាក្យសុំចូលបំរើការងារលេខ ១៥-៩៥ ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៩៥របស់មន្ទីរធម្មការ និង សាសនាខេត្តកំពង់ឆ្នាំង ។

សំរេច

ប្រការ ១ : យល់ព្រមបញ្ចូលកញ្ញា **ចាន់ ថាវី** អោយបំរើការងារក្នុងមន្ទីរធម្មការ និង សាសនាខេត្ត កំពង់ឆ្នាំង ចាប់ពីថ្ងៃទី ០១-០៥-១៩៩៥ ។

ប្រការ ២ : បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗ របស់កញ្ញា **ចាន់ ថាវី** ចាប់អនុវត្តពីថ្ងៃ ០១-០៥-១៩៩៥តទៅ ។

ប្រការ ៣ : មន្ទីរធម្មការនិងសាសនាខេត្ត សាលាខេត្ត មន្ទីរផែនការខេត្ត មន្ទីរហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង និង សាម៉ីខ្លួនត្រូវអនុវត្តរៀងៗខ្លួន ។

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

ហត្ថលេខានិងត្រា

ហៀង ចណ្ណារ័ត្ន

***

៦.រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ : ២៤៧ មស.ប្រក

ស្តីពីការកែតម្រូវសេចក្តីសំរេចលេខ ១៧៥ សសរ មស.ប្រក ចុះថ្ងៃទី ២២.០៣.១៩៩៥

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។

-បានឃើញព្រះរាជក្រឹត្យលេខ : នស.រកត ១២៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។

-យោងសេចក្តីសំរេចលេខ ១៧៥ សសរ.មស.ប្រក ចុះថ្ងៃទី ២២-០៣-១៩៩៥ របស់រដ្ឋលេខាធិការ ដ្ឋានមុខងារសាធារណៈ ។

-យោងលិខិតលេខ ១៣១_៩៥ មពស ចុះថ្ងៃទី ០៣_០៤_៩៥ របស់នាយកមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ។

សំរេច

ប្រការ ១ : កែតម្រូវតារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ១៧៥ សសរ.មស.ក្រខ ចុះថ្ងៃទី ២២_០៣_១៩៩៥ របស់រដ្ឋលេខាធិការមុខងារសាធារណៈដូចតទៅ :

ល.រ	នាមត្រកូលនិងនាមខ្លួន	ភេទ	ថ្ងៃខែឆ្នាំកំណើត	អង្គភាពដើម	មុខជំនាញបច្ចេកទេស បណ្តុះបណ្តាល	អង្គភាពចូល បំរើការងារ	បៀវត្ស
			ខ្លឹមសារ				
១៩០	ពុធ សុធីរិទ្ធ	ស្រី	១៥-០១-៧០	សិស្ស	ស.កកសិកម្មឧត្តម	ក្រ.ឧស្សាហកម្ម	៩០ ឱ.១
			ខ្លឹមសារកែតម្រូវ				
១៩០	ពុធ សុធីរិទ្ធ	ស្រី	១៥-០១-៧០	សិស្ស	ស.កកសិកម្មឧត្តម	ក្រ.កសិកម្ម	៩០ ឱ.១

ប្រការ ២ : រាល់ខ្លឹមសារផ្សេងៗពីប្រការនេះ រក្សាទុកដដែល ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានក្របខ័ណ្ឌ នាយកដ្ឋានបៀវត្ស ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីជន ត្រូវអនុវត្តសេចក្តីសំរេចនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ញាត់ សុខ

***

បោះពុម្ពនៅរោងពុម្ពទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

ឆ៊ីខែ ៣៧៨